**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខៈ ៨៦៨២ ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការគ្រប់គ្រង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍ ចំពោះអំពើល្មើសនឹងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
|---|---|---|
| **ក្រសួងមហាផ្ទៃ** | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងបរិស្ថាន** |

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- បានឃើញបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

## សម្រេច

**ប្រការ១.-**

ការគ្រប់គ្រង និងការប្រើប្រាស់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ចំពោះអំពើល្មើសនឹងទោសបញ្ញត្តិនានាដែលមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក។

**ប្រការ២.-**

រដ្ឋបាលរាជធានី ត្រូវរៀបចំគណៈកម្មការទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍រាជធានី ចំពោះអំពើល្មើសនានាដែលមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

គណៈកម្មការទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍រាជធានី មានតួនាទីដឹកនាំ គ្រប់គ្រង ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់គោលការណ៍ណែនាំអំពីការអនុវត្តការពិន័យអន្តរការណ៍នៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរាជធានី។

គណៈកម្មការនេះ ត្រូវមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលរាជធានី | ប្រធាន |
| - អភិបាលរងរាជធានីទទួលបន្ទុកការងារបរិស្ថាន | អនុប្រធាន |
| - ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| - ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងស្នងការដ្ឋាននគរបាលរាជធានី | សមាជិក |
| - អភិបាលខណ្ឌទាំងអស់ | សមាជិក |
| - នាយកទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់ | សមាជិក។ |

គណៈកម្មការនេះ អាចបន្ថែមសមាសភាពអ្នកពាក់ព័ន្ធមួយចំនួនជាសមាជិកតាមការចាំបាច់។

ការបង្កើតគណៈកម្មការទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍ ត្រូវដាក់ចេញដោយដីការបស់រដ្ឋបាលរាជធានី។

**ប្រការ៣._**

គណៈកម្មការទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍រាជធានី ត្រូវបង្កើតក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍តាមរដ្ឋបាលខណ្ឌនីមួយៗ ដើម្បីជួយដល់គណៈកម្មការក្នុងការអនុវត្តការពិន័យអន្តរការណ៍នៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលខណ្ឌនីមួយៗ។

ក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍នីមួយៗ ត្រូវមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលខណ្ឌ | ប្រធាន |
| - តំណាងមន្ទីរបរិស្ថាន | សមាជិក |
| - តំណាងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងអធិការដ្ឋាននគរបាលខណ្ឌ | សមាជិក |
| - ចៅសង្កាត់ទាំងអស់ | សមាជិក |
| - នាយប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ទាំងអស់ | សមាជិក |
| - មន្ត្រីរដ្ឋបាលខណ្ឌទទួលបន្ទុកការងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន | សមាជិក។ |

ក្រុមការងារនេះ អាចបន្ថែមសមាសភាពអ្នកពាក់ព័ន្ធមួយចំនួនជាសមាជិកតាមការចាំបាច់។

ការបង្កើតក្រុមការងារនេះ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលរាជធានី។

រដ្ឋបាលខណ្ឌនីមួយៗ អាចរៀបចំឱ្យមានភ្នាក់ងារអនុវត្តការពិន័យអន្តរការណ៍ តាមគោលដៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់។ ការរៀបចំភ្នាក់ងារនេះត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលខណ្ឌ។

**ប្រការ៤.-**

រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍ក្រុង ស្រុក ចំពោះអំពើល្មើសនានាដែលមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

ក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍ក្រុង ស្រុក មានតួនាទីដឹកនាំ គ្រប់គ្រង និងអនុវត្តការពិន័យអន្តរការណ៍នៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលក្រុង ស្រុករបស់ខ្លួន។

ក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍ក្រុង ស្រុក ត្រូវមានសមាសភាពដូចខាងក្រោមៈ

- អភិបាលក្រុង ស្រុក ប្រធាន
- តំណាងមន្ទីរបរិស្ថាន សមាជិក
- តំណាងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងអធិការដ្ឋាននគរបាលក្រុង ស្រុក សមាជិក
- មេឃុំ ចៅសង្កាត់ទាំងអស់ សមាជិក
- នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ទាំងអស់ សមាជិក
- មន្ត្រីរដ្ឋបាលក្រុង ស្រុកទទួលបន្ទុកការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន សមាជិក។

ក្រុមការងារនេះ អាចបន្ថែមសមាសភាពអ្នកពាក់ព័ន្ធមួយចំនួនជាសមាជិកតាមការចាំបាច់។

ការបង្កើតក្រុមការងារនេះ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលក្រុង ស្រុក។

ក្រុមការងារនេះ អាចរៀបចំឱ្យមានភ្នាក់ងារអនុវត្តការពិន័យអន្តរការណ៍ តាមគោលដៅនីមួយៗ តាមការចាំបាច់។ ការរៀបចំភ្នាក់ងារនេះ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលក្រុង ស្រុក។

**ប្រការ៥.-**

រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក អាចកំណត់អំពីបែបបទនៃការបង់ប្រាក់ពិន័យអន្តរការណ៍ ការប្រមូល និងការគ្រប់គ្រងប្រាក់ពិន័យអន្តរការណ៍។

**ប្រការ៦.-**

អំពើល្មើស និងចំនួនទឹកប្រាក់នៃការពិន័យអន្តរការណ៍ ត្រូវអនុវត្តឱ្យស្របតាមមាត្រា៣៩ មាត្រា៤០ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ មាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩ នៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដូចមានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ៧.-**

ការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនានាដែលមានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធ ដូចមានចែងក្នុងប្រការ៦នៃប្រកាសអន្តរក្រសួងនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលដាក់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨.-**

ប្រាក់ចំណូលដែលប្រមូលបានពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងទោសបញ្ញត្តិ ដូចមានកំណត់ក្នុងជំពូកទី៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវបានបែងចែកជាចំណែកសម្រាប់បង់ចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិសាមី ចំណែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិសាមី ចំណែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ផ្តល់ជូនមន្ទីរបរិស្ថាន និងចំណែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ផ្តល់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប្រាក់ចំណូលនេះ ត្រូវបែងចែកផ្អែកតាមសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលដែលប្រមូលបានតាមអត្រាកំណត់ដូចខាងក្រោម៖

- ចំណែកសម្រាប់បង់ចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិសាមី ចំនួន ៥០%
- ចំណែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិសាមី ចំនួន ៤៤%
- ចំណែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ផ្តល់ជូនមន្ទីរបរិស្ថាន ចំនួន ៥%
- ចំណែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ផ្តល់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១%។

**ប្រការ៩.-**

ចំណែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិសាមី ត្រូវបែងចែកសម្រាប់លើកទឹកចិត្តជូនបុគ្គលិក និងភ្នាក់ងារអនុវត្តការពិន័យអន្តរការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន យ៉ាងច្រើនចំនួន ៧០% និងចំណាយសម្រាប់ពង្រឹងយន្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនយ៉ាងតិចចំនួន ៣០%។

ការកំណត់បែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់បុគ្គលិក និងភ្នាក់ងារអនុវត្តពិន័យអន្តរការណ៍ និងចំណាយសម្រាប់ពង្រឹងយន្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវសម្រេចដោយគណៈកម្មការទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍រាជធានី ឬក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍ក្រុង ស្រុក។

ការបែងចែកប្រាក់រង្វាន់សម្រាប់ចំណាយលើកទឹកចិត្តដូចបានកំណត់ខាងលើនេះ ត្រូវបានផ្តល់អាទិភាពជូនបុគ្គលិក និងភ្នាក់ងារបំពេញការងារផ្ទាល់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**ប្រការ១០.-**

អនុញ្ញាតឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកសាមីកាត់ទុកប្រាក់ចំណូលចំនួន៥០% ពីប្រាក់ចំណូលសរុបដែលប្រមូលបានពីការពិន័យអន្តរការណ៍ ដើម្បីចាត់ចែងបើកផ្តល់ជាចំណែកប្រាក់រង្វាន់

លើកទឹកចិត្តសម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិសាមី មន្ទីរបរិស្ថាន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចបានកំណត់ក្នុងប្រការ៨នៃប្រកាសអន្តរក្រសួងនេះ។

រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកសាមីត្រូវទទួលខុសត្រូវលើប្រាក់ចំណូលដែលប្រមូលបាន ដោយត្រូវរៀបចំសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី ចំនួន ៥០% ព្រមទាំងបង់ចំណែកប្រាក់រង្វាន់សម្រាប់ផ្តល់ជូនមន្ទីរបរិស្ថាន ចំនួន ៥% និងបង់ចំណែកប្រាក់រង្វាន់សម្រាប់ផ្តល់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១%។

រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកសាមីមានភារកិច្ចបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ប្រាក់រង្វាន់សរុប និងរៀបចំសលាកបត្របង់ចំណូលថវិកាស្មើនឹងចំនួនទឹកប្រាក់រង្វាន់សរុបដែលបានកាត់ទុក។

**ប្រការ១១.-**

ការបើកផ្តល់ និងការប្រើប្រាស់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តដូចខាងក្រោម៖

ក. ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តជូនបុគ្គលិក និងភ្នាក់ងារអនុវត្តការពិន័យអន្តរការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវអនុលោមតាមការសម្រេចរបស់អភិបាលរាជធានី អភិបាលក្រុង និងអភិបាលស្រុកសាមី ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តជូនបុគ្គលិកមន្ទីរបរិស្ថាន ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

គ. ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តជូនបុគ្គលិកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ឃ. ការប្រើប្រាស់ប្រាក់ចំណាយសម្រាប់ពង្រឹងយន្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវអនុលោមតាមការសម្រេចរបស់អភិបាលរាជធានី អភិបាលក្រុង និងអភិបាលស្រុកសាមី។

**ប្រការ១២.-**

ការគ្រប់គ្រង និងការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីជាធរមានដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៣.-**

រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយនូវខ្លឹមសារនៃប្រកាសអន្តរក្រសួងនេះក្នុងរយៈពេល០៦ខែ ចាប់ពីថ្ងៃចេញប្រកាសអន្តរក្រសួងនេះ និងត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុលើការជំទាស់ ឬការមិនសុខចិត្តរបស់អ្នកប្រព្រឹត្តអំពើល្មើសនឹងទោសបញ្ញត្តិ ដូចមានកំណត់ក្នុងជំពូកទី៧នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ចំពោះការអនុវត្តការពិន័យអន្តរការណ៍របស់បុគ្គលិក និងភ្នាក់ងារអនុវត្តការពិន័យអន្តរការណ៍។

**ប្រការ១៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធដែលស្ថិតក្រោមឱវាទក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ...អង្គារ ១២កើត...ខែ...ភទ្របទ.....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១០..... ខែ...កញ្ញា... ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប

  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ១៤

  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ